ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៥-២១២ប្រក

# ប្រកាស

## ស្តីពី

## វិសោធនកម្មលើប្រកាសស្តីពី និតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

## សំរេច

**ប្រការ ១.-**

ធ្វើវិសោធនកម្មប្រការ៣ នៃប្រកាសលេខធ៧-០២-២០៣ប្រក ចុះថ្ងៃទី១៧ខែតុលា ឆ្នាំ២០០២ ស្តីពីនិតិវិធីជាបទដ្ឋានសំរាប់សកម្មភាពកែតម្រូវបន្ទាន់ ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានខ្លឹមសារដូចតទៅ :

តាមនិតិវិធីសកម្មភាពកែតម្រូវបន្ទាន់ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបែងចែកជាប្រភេទ ដោយផ្អែកលើអនុបាតសាធនភាពរបស់ខ្លួនដូចបានកំណត់ក្នុងប្រកាសវិសោធនកម្មស្តីពីអនុបាតសាធនភាព ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានចាត់ថា ÷

ក. មានដើមទុនល្អប្រសើរ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស២០ភាគរយ

ខ. មានដើមទុនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស១៥ភាគរយ ប៉ុន្តែស្ថិតនៅក្រោម២០ភាគរយ

គ. មានដើមទុនមិនគ្រប់គ្រាន់ នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ១០ភាគរយ ប៉ុន្តែស្ថិតនៅក្រោម ១៥ភាគរយ

ឃ. ខ្វះដើមទុនច្រើន នៅពេលអនុបាតសាធនភាពរបស់ខ្លួនស្មើ ឬលើស ៥ភាគរយ ប៉ុន្តែស្ថិតនៅក្រោម១០ភាគរយ

ង. ខ្វះដើមទុនធ្ងន់ធ្ងរ នៅពេលអនុបាតសាធនភាពរបស់ខ្លួននៅក្រោម៥ភាគរយ ។

**ប្រការ ២.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៣.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២ " ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA

NATION RELIGION KING

Unofficial Translation

NATIONAL BANK OF CAMBODIA

Number B7.05-212 Prokor

# PRAKAS
# on
# Amendment of Prakas

## Standardized Procedures for Prompt Corrective Action for Banking and Financial Institutions

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27, dated January 26, 1996 promulgating the Law on the Organization and conduct of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/0904/244 of 7 September 2004 on the appointment of His Excellency Chea Chanto as Governor of the National Bank of Cambodia;
- Pursuant to the request of the banking supervision department;

## DECIDES

**Article 1.**

Article 3 of Prakas No. B7-02-203 dated 17 October, 2002 relating to the standardized procedures for prompt corrective action for banking and financial institutions is amended as following:

Under the prompt corrective action procedures, the banks and financial institutions will be categorized based on their solvency ratio, as previously defined in the amendment of Prakas on Solvency Ratio of Banks. A bank and financial institution is classified as:

a. Well-Capitalized when its solvency ratio equals or exceeds 20 percent.

b. Adequately Capitalized when its solvency ratio equals or exceeds 15 per cent, but is less than 20 percent

c. Undercapitalized when its solvency ratio equals or exceeds 10 percent, but is less than 15 percent

d. Significantly Undercapitalized when its solvency ratio equals or exceeds 5 percent, but is less than 10 percent.

P.O Box 25, 22-24 Preah Norodom Blvd., Phnom Penh, Cambodia

Phone : 855 23 722563
Fax/Phone : 855 23 426117

e. Critically Undercapitalized when its solvency ratio is less than 5 percent.

**Article 2.**

The General Direction, the General Secretariat, the General Inspection, the General Cashier, all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 3.**

This Prakas shall have effect from the signing date.

Phnom Penh, 29 November, 2005

**The Governor**

**Signed and sealed: Chea Chanto**

cc:
- The Members of the Board of Directors
- The parties concerned as stated in Article 2
- File
- CM "for info"
- Administration of CM "for publication in the National Gazette"